# សេចក្តីណែនាំអំពី
# ការអនុវត្តវិធានផ្តល់ឥណទាន

ខែមីនា ឆ្នាំ២០២២

# មាតិកា


សេចក្តីសង្ខេប ........ ១

I. សេចក្តីផ្តើម ........ ៣

II. គោលបំណង ........ ៣

III. ដែនកំណត់នៃការអនុវត្ត ........ ៣

១. ការអនុវត្ត និងអនុលោមភាព ........ ៣

២. ទីផ្សារដែលត្រូវអនុវត្តវិធានផ្តល់ឥណទាន ........ ៤

IV. ក្រុមអនុវត្តនៃការផ្តល់ឥណទាន ........ ៤

១. ការបញ្ជូនទិន្នន័យ ........ ៤

២. វិធានពហុស្ថាប័នផ្តល់កម្ចី ........ ៥

៣. វិធានបុនហិរញ្ញប្បទាន ........ ៥

V. ការត្រួតពិនិត្យនិងការរាយការណ៍ ........ ៦

១. ឧបករណ៍តាមដានត្រួតពិនិត្យ ដែលបានបង្កើតឡើងក្នុងកម្មវិធី Excel ........ ៧

២. Dashboard ត្រួតពិនិត្យវិធានផ្តល់ឥណទានសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ........ ៨

VI. ការពង្រឹងការអនុវត្ត ........ ៩

# សេចក្តីសង្ខេប

វិស័យហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានទទួលស្គាល់ថាជាវិស័យមួយ ក្នុងចំណោមវិស័យដ៏មានសក្តានុពល ជាមួយនឹងកំណើនគួរឱ្យកត់សម្គាល់ និងមាននិរន្តរភាព។ វិស័យនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងធ្វើឱ្យប្រសើរឡើងនូវបរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់ផលិតផល និងសេវាហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា។ សមិទ្ធផលទាំងនេះ គឺសម្រេចបានក្រោមការគាំទ្រ និងចង្អុលបង្ហាញពីធនាគារជាតិនៃកម្ពុជា និងកិច្ចសហការពីដៃគូពាក់ព័ន្ធរួមមាន គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់វិស័យនេះ។

ដើម្បីការពារហានិភ័យនៃបំណុលច្រើនលើសលុបរបស់អតិថិជន ព្រមទាំងហានិភ័យដែលអាចកើតមានចំពោះវិស័យ សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានដាក់ចេញនូវមូលដ្ឋានក្នុងការទទួលខុសត្រូវរបស់ខ្លួនក្នុងការរក្សានិរន្តរភាព និងភាពធន់នៃវិស័យហិរញ្ញវត្ថុ ដោយចាប់ផ្តើមយ៉ាងសកម្មនូវវិធានដែលរួមចំណែកដល់កំណើន ប្រកបដោយសុខភាពល្អនៃវិស័យនេះ។ លើសពីនេះក្រុមប្រឹក្សាភិបាលនៃសមាគមធនាគារនៅកម្ពុជា និងក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានអនុម័តពង្រីកវិសាលភាពនៃការអនុវត្តប្រកបដោយគុណភាព ដើម្បីធានាបាននូវនិរន្តរភាពនៃវិស័យ តាមរយៈការដាក់បញ្ចូលវិធានផ្តល់ឥណទាននេះ ឱ្យក្លាយជាផ្នែកមួយនៃក្រមប្រតិបត្តិសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ។

វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការវិវត្តយ៉ាងឆាប់រហ័ស ខណៈតម្រូវការឥណទានសម្រាប់សហគ្រាសមីក្រូ និងសហគ្រាសធុនតូច និងមធ្យម មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះដែលទាមទារឱ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុពង្រីកវិសាលភាពនូវសេវានិងផលិតផលរបស់ខ្លួនទៅកាន់អតិថិជនគោលដៅទាំងអស់នេះ។ វាច្បាស់ណាស់ថា វិធានផ្តល់ឥណទានត្រូវមានឥទ្ធិពលលើប្រតិបត្តិករហិរញ្ញវត្ថុទាំងអស់ ដែលផ្តល់សេវាឥណទានដល់ទីផ្សារហិរញ្ញវត្ថុខ្នាតតូចនេះ។ ដូច្នេះ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រោមកិច្ចគាំទ្ររបស់គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុរបស់សមាគមធនាគារនៅកម្ពុជា បានបន្តធ្វើបច្ចុប្បន្នភាព "វិធានផ្តល់ឥណទាន" ដោយរួមបញ្ចូលទាំងគ្រឹះស្ថានធនាគារដែលជាសមាជិករបស់ សមាគមធនាគារនៅកម្ពុជា។

គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ របស់សមាគមធនាគារនៅកម្ពុជា បានអនុម័តក្នុងការអនុវត្តវិធានផ្តល់ឥណទានរបស់សមាគមទាំងពីរ ជាមួយនឹងឥណទានទាំងឡាយណាដែលមានទំហំរហូតដល់ ២០.០០០ ដុល្លារអាមេរិក (ពីរម៉ឺនដុល្លារអាមេរិក) តែមិនរាប់បញ្ចូលផលិតផលនិងសេវាដូចខាងក្រោម៖

- បណ្ណឥណទានដែលមានការធានា (Secured Credit Card)
- បណ្ណឥណទានដែលគ្មានការធានា (Unsecured Credit Card)
- បណ្ណឥណទានបញ្ចូលគ្នា (Combined Credit Card)
- បណ្ណឥណទានអាជីវកម្ម (Business Credit Card)
- ឥណទានវិបារូបរ៍ (Overdraft Facility)
- ឥណទានសម្រាប់ទុនបង្វិល (Revolving Loans)
- ឥណទានពាណិជ្ជកម្ម (Trade Finance Loans)
- ឥណទានទាំងឡាយណាដែលមានសមតុល្យ តិចជាង ១០% (<១០%) ធៀបនឹងទំហំឥណទានដើម

លក្ខខណ្ឌដែលបានស្នើឡើងនេះត្រូវបានយល់ព្រម និងអនុម័តដោយក្រុមប្រឹក្សាសមាគមធនាគារនៅកម្ពុជា និងក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

វិធានផ្តល់ឥណទាននេះ រួមបញ្ចូលនូវធាតុផ្សំសំខាន់ៗ ចំនួនបីខាងក្រោម៖

១. ការបញ្ជូនទិន្នន័យ

២. វិធាន ពហុស្ថាប័នផ្តល់កម្ចី

៣. វិធាន បុនហិរញ្ញប្បទាន

ដោយមានការគាំទ្រពីការិយាល័យឥណទានកម្ពុជា លើការរាយការណ៍ទិន្នន័យ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ទទួលបន្ទុកត្រួតពិនិត្យប្រសិទ្ធភាពលើការអនុលោមតាមវិធានទាំងនេះក្នុងចំណោមសមាជិករបស់ខ្លួន។ សមាគមទាំងពីរនឹងបន្តតាមដានត្រួតពិនិត្យ ព្រមទាំងស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អតាមតម្រូវការ និងភាពចាំបាច់។

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានស្នើសុំការអនុវត្តបណ្តោះអាសន្នលើវិធានផ្តល់ឥណទាន ពីខែកក្កដាដល់ខែធ្នូក្នុងឆ្នាំ២០២១។ សមាគមទាំងពីរបានប្រកាសជាផ្លូវការអំពីការអនុវត្តក្នុងអំឡុងពេលដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃក្រមប្រតិបត្តិសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។

# I. សេចក្តីផ្តើម

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានភាពរឹងមាំ និងរក្សាបានភាពធន់ខ្ពស់ និងបានចូលរួមគាំទ្រដល់ការអភិវឌ្ឍទាំងសេដ្ឋកិច្ចនិងសង្គម។ វិស័យនេះត្រូវបានទទួលស្គាល់ជាសកល ថាបានផ្តល់ជាឧទាហរណ៍អំពីភាពឈានមុខគេនៃឧស្សាហកម្មដែលគ្រប់គ្រងបានល្អ និរន្តរភាព និងថាមវន្ត ដែលបំពេញតម្រូវការរបស់អតិថិជន។

ទន្ទឹមនឹងការរីកចម្រើននេះ ការការពារហានិភ័យនៃបំណុលច្រើនលើសលុបរបស់អតិថិជន ព្រមទាំងហានិភ័យដែលអាចកើតមានចំពោះនៃវិស័យក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានដាក់ចេញនូវមូលដ្ឋាន ក្នុងការទទួលខុសត្រូវរបស់ខ្លួនក្នុងការរក្សានិរន្តរភាព និងភាពធន់នៃវិស័យហិរញ្ញវត្ថុ ដោយចាប់ផ្តើមយ៉ាងសកម្មនូវវិធានដែលរួមចំណែកដល់កំណើនប្រកបដោយសុខភាពល្អនៃវិស័យនេះ។ លើសពីនេះក្រុមប្រឹក្សាភិបាលនៃសមាគមធនាគារនៅកម្ពុជា និងក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានអនុម័ត ពង្រីកវិសាលភាពនៃការអនុវត្តប្រកបដោយគុណភាព ដើម្បីធានាបាននូវនិរន្តរភាពនៃវិស័យ តាមរយៈការដាក់បញ្ចូលវិធានផ្តល់ឥណទាន នេះឱ្យក្លាយជាផ្នែកមួយនៃក្រមប្រតិបត្តិសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ។

ជាផ្នែកសំខាន់មួយនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាអ្នកផ្តល់សេវាហិរញ្ញវត្ថុ ដល់ប្រជាជនកម្ពុជាភាគច្រើន ជាពិសេសអ្នកដែលងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងសង្គម សមាជិកនៃ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ទទួលស្គាល់សារៈសំខាន់បំផុតនៃការធានាបាននូវនិរន្តរភាពរយៈពេលវែងនៃវិស័យ សម្រាប់ជាប្រយោជន៍ដល់អតិថិជន និងប្រទេសទាំងមូល។ សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា រំលឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់ពួកខ្លួនចំពោះកំណើន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលធ្វើឱ្យមានតុល្យភាពនៃគោលដៅអាជីវកម្មជាមួយនឹងតម្រូវការដើម្បីការពារអតិថិជន និងរួមចំណែកដល់លទ្ធផលវិជ្ជមាននៅក្នុងជីវិតរបស់ពួកគេ។

# II. គោលបំណង

វិធានផ្តល់ឥណទានត្រូវបានបង្កើតឡើងដោយមានគោលបំណងសំខាន់ចំនួនបី៖

១. សមត្ថភាពខ្ចីរបស់អតិថិជនត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ
២. មានទិន្នន័យគ្រប់គ្រាន់ដើម្បីតាមដាននៃផលប៉ះពាល់ក្នុងកម្រិតគ្រឹះស្ថានចំពោះហានិភ័យជាប្រព័ន្ធ
៣. ការជំពាក់បំណុលច្រើន ការកើនឡើងយ៉ាងឆាប់រហ័សនៃបំណុលគ្រួសារ មូលហេតុសំខាន់នៃការជំពាក់បំណុលច្រើន និងការជំពាក់បំណុលជាយថាហេតុ ត្រូវបានកាត់បន្ថយ

# III. ដែនកំណត់នៃការអនុវត្ត

## ១. ការអនុវត្ត និងអនុលោមភាព

វិធានផ្តល់ឥណទាននេះ ត្រូវអនុវត្តចំពោះគ្រឹះស្ថានផ្តល់ប្រាក់កម្ចីទាំងអស់ នៅក្នុងប្រទេសកម្ពុជាដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូ

ហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានឥណទានជនបទ និងក្រុមហ៊ុនភិតិសន្យាហិរញ្ញវត្ថុ។

### ២. ទីផ្សារដែលត្រូវអនុវត្តវិធានផ្តល់ឥណទាន

លទ្ធផលនៃការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍វិធានផ្តល់ឥណទានសម្រាប់វិស័យហិរញ្ញវត្ថុ ក្នុងឆ្នាំ២០២០ បានបង្ហាញថា សរុបមកកម្រិតនៃបំណុលច្រើនលើសលុបគឺមានភាពស្រដៀងគ្នា ទាំងអតិថិជននៃសមាជិកសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ប៉ុន្តែចំនួនអតិថិជនដែលជំពាក់បំណុលច្រើនព្រមទាំងមានឥណទានធំជាង ២០.០០០ដុល្លារអាមេរិកនោះ គឺមានភាគតិចតួចបំផុត ដោយរួមទាំងអតិថិជនដែលមានឥណទានច្រើនគ្រឹះស្ថាន (ឧ. ឥណទានសកម្ម ជាមួយគ្រឹះស្ថានផ្តល់ឥណទានលើសពី ៣គ្រឹះស្ថាន (> ៣)។ ដូច្នេះហើយទើប គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ របស់សមាគមធនាគារនៅកម្ពុជា បានយល់ព្រមកំណត់ទីផ្សារដើម្បី អនុវត្តវិធានផ្តល់ឥណទានរបស់សមាគមទាំងពីរ ជាមួយនឹងឥណទានទាំងឡាយណាដែលមានទំហំរហូតដល់ ២០.០០០ដុល្លារអាមេរិក (ពីរម៉ឺនដុល្លារអាមេរិក) តែមិនរាប់បញ្ចូលផលិតផលនិងសេវាដូចខាងក្រោម៖

- បណ្ណឥណទានដែលមានការធានា (Secured Credit Card)
- បណ្ណឥណទានដែលគ្មានការធានា (Unsecured Credit Card)
- បណ្ណឥណទានបញ្ចូលគ្នា (Combined Credit Card)
- បណ្ណឥណទានអាជីវកម្ម (Business Credit Card)
- ឥណទានវិបារូបន៍ (Overdraft Facility)
- ឥណទានសម្រាប់ទុនបង្វិល (Revolving Loans)
- ឥណទានពាណិជ្ជកម្ម (Trade Finance Loans)
- ឥណទានទាំងឡាយណាដែលមានសមតុល្យ តិចជាង ១០% (<១០%) ធៀបនឹងទំហំឥណទានដើម

ដោយសារមិនមានស្តង់ដារទូទៅសម្រាប់ការគណនា ឬផ្ទៀងផ្ទាត់ប្រាក់ចំណូលរបស់អតិថិជននៅក្នុងផ្នែកនេះ ដូច្នេះកម្រិតបំណុលសរុប (ការបង់រំលស់ប្រចាំខែសម្រាប់ឥណទានដែលមានស្រាប់ និងឥណទានថ្មីធៀបនឹងប្រាក់ចំណូល) របស់អតិថិជន គឺមិនអាចប្រើប្រាស់ដើម្បីកំណត់ថា គ្រឹះស្ថានបានបំពានដែនកំណត់នៃវិធានឥណទាន បី (៣) គ្រឹះស្ថាន ឬច្រើនជាងនេះឡើយ។

## IV. ក្រមអនុវត្តនៃការផ្តល់ឥណទាន

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានដាក់ចេញនូវវិធានចំនួនបី ដែលមានចែងនៅក្នុងវិធានផ្តល់ឥណទានដែលរួមមាន៖

### ១. ការបញ្ជូនទិន្នន័យ

វិធានផ្តល់ឥណទានតម្រូវឱ្យ រាល់ប្រាក់កម្ចីដែលបានបញ្ចេញថ្មី និងបិទទាំងអស់ តែត្រូវបានរាយការណ៍ទៅការិយាល័យឥណទានកម្ពុជា រៀងរាល់សប្តាហ៍ក្នុងអំឡុងពេល ០៥ថ្ងៃធ្វើការ ហើយត្រូវពង្រឹងការ

គ្រប់គ្រង និងត្រួតពិនិត្យឱ្យបានជាក់លាក់នូវទិន្នន័យទាក់ទងនឹងទិន្នន័យហិរញ្ញវត្ថុ (រួមទាំងព័ត៌មានលម្អិតអំពីអត្តសញ្ញាណផ្ទាល់ខ្លួន) ដែលបញ្ជូនទៅកាន់ការិយាល័យឥណទានកម្ពុជា។

## ២. វិធានពហុស្ថាប័នផ្ដល់កម្ចី

មិនត្រូវបញ្ចេញប្រាក់កម្ចីដល់អ្នកខ្ចីណា (ជាក្រុម និង/ឬបុគ្គល) ដែលកំពុងមានកម្ចីចំនួន ០៣ គ្រឹះស្ថាន ឬច្រើនជាងឡើយ។ គ្រឹះស្ថានអាចនឹងបញ្ចេញបាន ប៉ុន្តែមិនត្រូវលើស២% ដែលជាដែនកំណត់អតិបរមានៃការបំពានវិធានពហុស្ថាប័នផ្ដល់កម្ចី។

## ៣. វិធានបុនហិរញ្ញប្បទាន

ការផ្ដល់បុនប្បទាននៅតែជាធាតុផ្សំដ៏សំខាន់នៃវិធានផ្ដល់ឥណទាន។ ការផ្ដល់បុនហិរញ្ញប្បទានសំដៅលើការអនុវត្ត នៅពេលដែលអតិថិជនជំនួសប្រាក់កម្ចីសកម្ម ជាមួយនឹងឥណទានថ្មីដែលមានទំហំធំជាង។ វាបានដើរតួនាទីយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រ អាជីវកម្មរបស់គ្រឹះស្ថានដែលផ្ដល់ឥណទានខ្នាតធំ ឥណទានខ្នាតតូច និងឥណទានខ្នាតមីក្រូ។ វិធានស្ដីពីការផ្ដល់បុនហិរញ្ញប្បទាន ត្រូវកំណត់តាមវិធីសាស្ត្រដូចខាងក្រោម៖

ក. ការអនុវត្តនូវវិធាន

ការកំណត់ទៅលើការផ្ដល់ឥណទាន ត្រូវអនុវត្តចំពោះការចេញឥណទានថ្មីដល់អតិថិជនក្នុងរង្វង់ ១៥ថ្ងៃ មុន ឬក្រោយ ការបង់ផ្ដាច់ឥណទានដែលមានស្រាប់ និងមុនថ្ងៃផុតកំណត់ផ្លូវការ។ វិធាននេះត្រូវបានអនុវត្តមិនថាតែឥណទានទាំងពីរ (បញ្ចេញថ្មី និងសងផ្ដាច់) ដែលត្រូវបានចេញដោយគ្រឹះស្ថានផ្សេងគ្នា ឬគ្រឹះស្ថានតែមួយ។

ខ. សូចនាករពេលវេលា

រយៈពេលខ្ចីរបស់អតិថិជន ត្រូវបានកំណត់ជាបីដំណាក់កាល (Trimesters) ស្មើៗគ្នា។ ឧទាហរណ៍ កម្ចីដែលមានរយៈពេល ១ឆ្នាំ (១២ខែ) មានដំណាក់កាលនីមួយៗគឺ ៤ខែ ដូច្នេះខែទី៤ គឺស្ថិតនៅក្នុងដំណាក់កាលទីមួយ ហើយខែទី៥ គឺនៅក្នុងដំណាក់កាលទីពីរ។ សម្រាប់ឥណទានរយៈពេល ៣ឆ្នាំ (៣៦ខែ) ខែទី២០ គឺនៅក្នុងដំណាក់កាលទីពីរ ហើយខែទី៣០ គឺនៅក្នុងដំណាក់កាលទីបី។

គ. សូចនាករទំហំឥណទាន

ទំហំនៃការផ្ដល់បុនហិរញ្ញប្បទាន ត្រូវបានគណនាដូចតទៅ៖ ចំនួនសរុបនៃឥណទានថ្មី(ដែលបានបញ្ចេញដោយគ្រឹះស្ថាន) ចែកនឹងចំនួនដើមនៃឥណទានចាស់ (បង់ផ្ដាច់)។ ក្នុងករណីដែលឥណទានច្រើនជាងមួយត្រូវបានធ្វើបុនហិរញ្ញប្បទាន នោះចំនួនឥណទានទាំងនោះនឹងត្រូវសរុបរួមគ្នា។ **ឧទាហរណ៍** មានកម្ចីច្រើនជាងមួយត្រូវបានធ្វើបុនហិរញ្ញប្បទានដោយឥណទានថ្មីតែមួយ ដូច្នេះចំនួនទឹកប្រាក់ឥណទានថ្មីនឹងត្រូវយកទៅចែកដោយចំនួនឥណទានដើម ដែលបានសរុបរួមគ្នានៃឥណទានដែលត្រូវសង។ **ឧទាហរណ៍** អតិថិជនម្នាក់ដែលមានឥណទាន ៥០០ ដុល្លារអាមេរិក ចំនួន២គ្រឹះស្ថាន ហើយជំនួសដោយឥណទានថ្មីចំនួន ១.២០០ដុល្លារអាមេរិក ពី១គ្រឹះស្ថាន នោះលទ្ធផលនឹងបង្ហាញថាមានការបង្កើនទំហំឥណទានដល់ ១២០%។ ប្រសិនបើចំនួនឥណទានដើម ដែលបានសរុបរួមគ្នានៃឥណទានដែលត្រូវបង់ ធំជាង ២០.០០០ ដុល្លារអាមេរិក នោះដែនកំណត់នៃការផ្ដល់បុនហិរញ្ញប្បទាន នឹងមិនត្រូវយកមកគណនានោះទេ។

ដោយផ្អែកលើសូចនាករទាំងនេះ ការផ្តល់បុនហិរញ្ញប្បទានត្រូវបានបែងចែកទៅជា ៣ "តំបន់"។ ទី១៖ "តំបន់ក្រហម" គឺជាឥណទានដែលស្ថិតក្នុងការផ្តល់បុនហិរញ្ញប្បទាន នៅដើមដំបូងនៃវដ្តកម្ចីរបស់អតិថិជនជាមួយនឹងឥណទានថ្មីដែលធំជាង។ ទី២៖ "តំបន់លឿង" គឺជាឥណទានដែល បានកើតឡើងនៅពេលបន្ទាប់ ហើយស្ថិតនៅក្នុងវដ្តនៃឥណទានចាស់ និង/ឬ ការផ្តល់ឥណទានថ្មីនោះបានធ្វើឱ្យមានការកើនឡើងក្នុងទំហំបន្តិចបន្តួចនៃបំណុលសរុប។ ចំណែកឯ ទី៣៖ "តំបន់បៃតង" គឺជាឥណទានដែលបានកើតឡើងនៅចុងបញ្ចប់នៃវដ្តកម្ចីនៃឥណទានចាស់ ហើយមានការកើនឡើងក្នុងទំហំបន្តិចបន្តួចនៃបំណុលសរុប។

វិធានផ្តល់ឥណទាននេះ បានកំណត់កម្រិត អតិបរមាត្រឹម ៥% សម្រាប់កម្ចីស្ថិតក្នុង "តំបន់ក្រហម" និង ១៥% សម្រាប់កម្ចីស្ថិតក្នុង "តំបន់លឿង"។ ឥណទានក្នុង "តំបន់បៃតង" គឺមិនមានការកំណត់កម្រិតអតិបរិមាឡើយ។ ដែនកំណត់អតិបរមាសម្រាប់ "តំបន់ក្រហម" ៥% នោះគឺមានន័យថាវិធានផ្តល់ឥណទានអនុញ្ញាតឱ្យគ្រឹះស្ថានបំពានវិធានបុនហិរញ្ញប្បទានក្នុង "តំបន់ក្រហម" បានខ្ពស់បំផុតត្រឹមតែ៥% តែប៉ុណ្ណោះ។ ដោយឡែកគ្រឹះស្ថានហិរញ្ញវត្ថុសាមី គួរតែព្យាយាមរក្សាកម្រិតឱ្យទាបដល់កម្រិតតិចជាង២% ចំពោះការបំពានក្នុង "តំបន់ក្រហម" នោះ។ ដែនកំណត់នេះត្រូវបានអនុម័តដោយ Smart Campaign ដែលបច្ចុប្បន្នគ្រប់គ្រងដោយ Social Performance Task Force (SPTF) និង CERISE ។

**រូបភាពទី១៖ ដែនកំណត់គិតជា % នៃចំនួនឥណទានដែលបានធ្វើបុនហិរញ្ញប្បទាន តាមប្រភេទនៃកម្រិតហានិភ័យ**

| ពេលវេលា/ទំហំឥណទាន | <១១០ | >=១១០ | >=១២០ | >=១៤០ | >=១៦០ | >=១៨០ | >=២០០ |
|---|---|---|---|---|---|---|---|
| ដំណាក់កាលទី១ | | | | | | | ៥% |
| ដំណាក់កាលទី២ | | | | ១៥% | | | |
| ដំណាក់កាលទី៣ | គ្មានដែនកំណត់ | | | | | | |

## V. ការត្រួតពិនិត្យនិងការរាយការណ៍

សមាជិកទាំងអស់នៃ សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នឹងទទួលបានរបាយការណ៍ប្រចាំខែពីការិយាល័យឥណទានកម្ពុជា ជាមួយនឹងសូចនាករសំខាន់ៗទាំងអស់ដែលមាននៅក្នុង Dashboard នៃវិធានផ្តល់ឥណទាន អំពីការអនុវត្តនៃវិធានខាងលើ។ ក្រៅពីនោះ ក្រុមការងារវិធានផ្តល់ឥណទាននឹងទទួលបានរបាយការណ៍នេះដូចគ្នា ហើយក្រុមការងារនឹងបញ្ចូលព័ត៌មានទាំងនោះទៅក្នុង ឧបករណ៍តាមដានត្រួតពិនិត្យ ដែលបានបង្កើតឡើងក្នុងកម្មវិធី Excel។ សមាជិកដែលបានចាត់តាំងពី លេខាធិការដ្ឋានសមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលធ្វើកិច្ចការងារលើវិធានផ្តល់ឥណទាននេះក៏នឹងត្រូវបានគេផ្តល់ឱ្យផងដែរ។ គ្មាននរណាម្នាក់ផ្សេងទៀតនៅក្នុង សមាគមធនាគារនៅកម្ពុជា ឬ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា រួមទាំងសមាជិកក្រុមប្រឹក្សាភិបាល មានសិទ្ធិចូលប្រើទិន្នន័យនេះទេ។ ខាងក្រោមនេះគឺជាគំរូនៃ dashboard សម្រាប់គ្រប់គ្រងនិងត្រួតពិនិត្យលើការអនុវត្តវិធាន។

## ១. ឧបករណ៍តាមដានត្រួតពិនិត្យ ដែលបានបង្កើតឡើងក្នុងកម្មវិធី Excel

ក្រាហ្វ ១: ការបំពានវិធានពហុស្ថាប័នផ្តល់កម្ចី




ក្រាហ្វ ២: ការបំពានវិធាន បុនហិរញ្ញប្បទាន – តំបន់ក្រហម




ក្រាហ្វ 3: ការបំពានវិធាន បុនហិរញ្ញប្បទាន – តំបន់លឿង



## ២. Dashboard ត្រួតពិនិត្យវិធានផ្តល់ឥណទានសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ



## VI. ការពង្រឹងការអនុវត្ត

បន្ទាប់ពីការដាក់ឱ្យដំណើរការជាផ្លូវការ គ្រឹះស្ថានផ្តល់ឥណទានទាំងអស់ដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តតាមវិធានទាំងនេះ ចាប់ពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២តទៅ។ គ្រឹះស្ថានផ្តល់ឥណទាន ណាមួយដែលមិនអនុលោមតាម វិធានបញ្ជូនទិន្នន័យ ដែនកំណត់លើចំនួនអតិថិជន (វិធានពហុស្ថាប័នផ្តល់កម្ចី) ការអនុវត្តការផ្តល់បុនហិរញ្ញប្បទាន ឬបំពានវិធាននានានៃវិធានផ្តល់ឥណទាន នឹងត្រូវបានរកឃើញ តាមរយៈយន្តការនៃការត្រួតពិនិត្យ។ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នឹងធ្វើការងារជាមួយនឹងការិយាល័យឥណទានកម្ពុជា ដើម្បីធ្វើការត្រួតពិនិត្យ ព្រមទាំងរាយការណ៍អំពីលទ្ធផលនៃការអនុវត្តវិធានផ្តល់ឥណទាននេះ ជូនដល់ក្រុមប្រឹក្សាភិបាលរបស់សមាគមទាំងពីររៀងរាល់៣ខែម្តង៕

ASSOCIATION OF BANKS IN CAMBODIA

CAMBODIA MICROFINANCE ASSOCIATION